# កិច្ចតែងការបង្រៀន

ថ្ងៃចន្ទ២រោចខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ ២៥៦៩
ត្រូវនឹងថ្ងៃទី១១ខែសីហាឆ្នាំ២០២៥

- មុខវិជ្ជា៖ ចិត្តចលភាព
- ប្រធានបទ៖  ការរីកចម្រើនរាងកាយ និងចលនា
- សកម្មភាពគោល៖ ល្បែង
- ចំណងជើងមេរៀន ៖ «វង្វង់ពាក្យផ្ទុយ»
- ថ្នាក់កម្រិត ខ្ពស់
- រយ:ពេល ៣០នាទី

១.វត្ថុបំណង

- វិជ្ជាសម្បទា៖ កុមារប្រាប់បានពីពាក្យផ្ទុយ ខ្ពស់ ទាប យឺត លឿន បានត្រឹមត្រូវតាមរយ: ការលេងល្បែង( វង្វង់ពាក្យផ្ទុយ )តាមរយ:ការណែនាំរបស់គ្រូ។
- បំណិនសម្បទា៖ កុមារយល់បានពីពាក្យផ្ទុយ ខ្ពស់ ទាប យឺត លឿន បានត្រឹមត្រូវតាមរយ:ការអនុវត្តជាក្រុមធំ។
- ចរិយាសម្បទា៖ បណ្តុះស្មារតីកុមារមានភាពតស៊ូ អត់ធ្មត់ ព្យាយាមក្នុងការលេងល្បែងវង្វង់ពណ៌បានល្អ។

២.ការរៀបចំ

- សម្ភារ:គ្រូ៖ ចាំពាក្យផ្ទុយដែលត្រូវលេង ក្រណាត់ផ្ទាំងធំរាងវង្វង់
- សម្ភារសិស្ស៖ គ្មាន
- ការរៀបចំ៖ ខាងក្រៅថ្នាក់រៀន

៣.ដំណើរការបង្រៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -រាប់ចំនួនកុមារ<br>-ពិនិត្យក្រចកដៃនិងសម្លៀកបំពាក់<br>-កូនៗអង្គុយឱ្យត្រង់ខ្លួន<br>-នាំកុមារធ្វើចលនារត់មួយកន្លែង( យឺត លឿន)<br><br>-កាលពីម្សិលមិញយើងហាត់ចិត្តចលភាពពីអ្វីដែរ? | ដំណាក់កាលទី១<br>+លំនឹងថ្នាក់<br>-ពិនិត្យអវត្តមាន<br>-ពិនិត្យអនាម័យ<br><br>-៣ផ្ទឹងសណ្តាប់ធ្នាប់<br>-ប្រមូលអារម្មណ៍<br><br>ដំណាក់កាលទី២<br>+រំឭកមេរៀនចាស់<br>-ល្បែង៖ រត់ប្រណាំងគ្នា | -នៅស្ងៀម<br>-ដាក់ជូនគ្រូពិនិត្យ<br><br>-អង្គុយត្រង់ខ្លួនស្តាប់គ្រូ<br>-ធ្វើទាំងអស់គ្នា<br><br>-ឆ្លើយ |

| | | |
|---|---|---|
| -ហៅកុមារ៥នាក់ឡើងមករត់ប្រណាំងគ្នា | | -រត់ប្រណាំងគ្នា |
| | +ទំនាក់ទំនងមេរៀនថ្មី | |
| -កូនៗចាំមើលអ្នកគ្រូធ្វើចលនារលាស់ក្រណាត់ឱ្យកូនមើល | | -មើល |
| -តើកូនឃើញអ្នកគ្រូរលាស់ក្រណាត់យ៉ាងមិចដែរ? | -រលាស់យឺត រលាស់លឿន | -ឆ្លើយ |
| | ជំហានទី៣<br>+មេរៀនថ្មី<br>-ល្បែង៖ រង្វង់ពាក្យផ្ទុយ<br>( លឿន យឺត ខ្ពស់ ទាប) | |
| -ព្រឹកនេះអ្នកគ្រូមានល្បែងសកម្មភាពមួយយកមកនាំកូនៗលេង | | -ស្តាប់ |
| -កូនៗចង់លេងជាមួយអ្នកគ្រូអត់? | | -ឆ្លើយ |
| -អ្នកគ្រូមានសម្ភារៈមកបង្ហាញកូន តើនេះជាអ្វី? | -ក្រណាត់ | -ឆ្លើយ |
| -តើមានពណ៌អ្វីខ្លះកូន? | -ខៀវ ក្រហម លឿង បៃតង | -ឆ្លើយរៀបរាប់ |
| -នាំកុមារអានចំណងជើងមេរៀន | -អានចំណងជើងមេរៀន | -អាន |
| +មុនលេងអ្នកគ្រូណែនាំកូនពីរបៀបលេងជាមុនសិន | -ណែនាំពីរបៀបលេង | -ស្តាប់ |
| -ដំបូងកូនៗត្រូវឈរជារង្វង់ ហើយកាន់ក្រណាត់ដែលមានរាងជារង្វង់ បន្ទាប់មកកូនត្រូវស្តាប់អ្នកគ្រូស្រែកប្រាប់ឱ្យកូនធ្វើចលនា។ ប្រសិនបើអ្នកគ្រូស្រែកថាយឺត កូនៗត្រូវរលាស់ក្រណាត់នេះយឺតដែរ ប្រសិនបើអ្នកគ្រូស្រែកថាលឿន កូនៗត្រូវរលាស់ក្រណាត់នេះលឿនដែរ |  | |

| | | |
|---|---|---|
| ហើយបើអ្នកគ្រូស្រែកថាខ្ពស់ កូនត្រូវលាស់ក្រណាត់នេះឡើងទៅលើ ហើយបើអ្នកគ្រូស្រែកថាទាប កូនត្រូវលាស់ក្រណាត់នេះចុះក្រោម។ ចឹងកូនៗយល់ដែរឬទេ? | | |
| -ឱ្យកុមារម្នាក់និយាយពីរបៀបលេងនេះឡើងវិញ | -និយាយឡើងវិញ | -ឡើងនិយាយឡើងវិញ |
| -ឱ្យកុមារចាប់ផ្តើមលេង គ្រូសម្របសម្រួល | -សម្របសម្រួល | -ស្តាប់និងអនុវត្ត |
| | ជំហានទី៤<br>ពង្រឹងមេរៀន | |
| -តើអំបាញ់មិញអ្នកគ្រូនាំកូនហាត់ចិត្តចលភាពពីអ្វី? | -ចិត្តចលភាព៖ ល្បែង រង្វង់ពាក្យផ្ទុយ( លឿន យឺត ខ្ពស់ ទាប) | |
| | ជំហានទី៥<br>បណ្តាំផ្ញើនិងលើកសរសើរ | |
| -ថ្ងៃនេះអ្នកគ្រូសប្បាយចិត្តដែលឃើញកូនៗយកចិត្តទុកដាក់ស្តាប់អ្នកគ្រូគ្រប់ៗគ្នា | -លើកសរសើរ | -ស្តាប់ |
| -ពេលត្រឡប់ទៅផ្ទះវិញកូនៗអាចលេងល្បែងនៅផ្ទះបានណា | -បណ្តាំផ្ញើ | -ចាស/បាទ |

ថ្ងៃចន្ទ២រោចខែស្រាពណ៍ ឆ្នាំម្សាញ់ឆស័កព.ស២៥៦៩
ត្រូវនឹងថ្ងៃទី១១ខែសីហា ឆ្នាំ២០២៥
គ្រូបន្ទុកថ្នាក់

មាន សុផា

**បានឃើញនិងឯកភាព**
**នាយិកាសាលា**

អ៊ុំ ណារឿន